# សង្គមវិទ្យាក្នុងព្រះពុទ្ធសាសនា

SOCIOLOGY IN BUDDHISM

ការសិក្សាទៅលើសង្គមវិទ្យាក្នុងព្រះពុទ្ធសាសនា មានលក្ខណៈទូលំទូលាយនិងស៊ីជំរៅណាស់។ ប៉ុន្តែពេលនេះ សូមអធិប្បាយត្រួសៗនិងដោយសង្ខេប ទៅលើសារៈសំខាន់ខ្លះៗដែលយើងគួរដឹងចំពោះអមតធម៌របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទៅនឹងពាក្យថាសង្គមវិទ្យា ។

## សិទ្ធិមនុស្ស និង សិទ្ធិសត្វ

Human Rights and Animal Rights

បញ្ចសីលឬសីលប្រាំ ជាចរិយធម៌មូលដ្ឋានរបស់មនុស្សទូទៅ ដោយមិនកំណត់ចំពោះតែក្រុមជំនឿសាសនា និន្នាការ ពណ៌សំបុរ ភាសា វប្បធម៌ ឬជនជាតិនិមួយៗឡើយ។ សីលប្រាំឬនិច្ចសីលនេះមានរួចទៅហើយក្នុងធម្មជាតិយើងនេះ មានលក្ខណៈរស់រវើក និងត្រចះត្រចង់រក្សាមនុស្សលោកឱ្យមានសេចក្តីសុខសន្តិភាព មិនប្រកាន់បក្សពួក វណ្ណៈ និន្នាការអ្វីឡើយ បើគេទាំងអស់នោះយកសីលប្រាំទុកជាសម្បត្តិក្នុងក្រអៅបេះដូងរបស់ពួកគេ ។

សីលទីមួយ ក្នុងចំណោមសីលទាំងប្រាំ ព្រះសម្មាសម្ពុទ្ធជាម្ចាស់បញ្ជាក់ប្រាប់យើងថា “ *ចូរវៀរចាកការប្រព្រឹត្តកន្លងរំលោភទៅលើសត្វមានជីវិត មានការសំលាប់សត្វជាដើម* ” ។ ការវៀរចាកនេះ មិនមែនប្រព្រឹត្តត្រឹមតែការសំឡាប់ទេ សូម្បីតែមានការបៀតបៀន ធ្វើទុក្ខបុកម្នេញធ្វើឱ្យរបួសស្នាម គំរាមគំហែងឬបំភិតបំភ័យ ក៏ចាត់ទុកថាយើងប្រព្រឹត្តខុសសីលខទីមួយនេះផងដែរ

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់នៅក្នុងគម្ពីរធម្មបទថា :

“ មនុស្សសត្វទាំងឡាយនឹងញាប់ញ័រនៅចំពោះមុខការគំរាមគំហែង។ មនុស្សសត្វទាំងឡាយភ័យខ្លាចសេចក្តីស្លាប់។ មនុស្សសត្វទាំងឡាយស្រឡាញ់ជីវិត។ ចូរសំឡឹងមើលខ្លួនអ្នកថាដូចជាអ្នកដទៃ។ ហើយនរណាដែលយើងអាចធ្វើឱ្យចុកចាប់។ ការឈឺផ្សាអ្វីដែលអ្នកអាចធ្វើទៅលើគេកើត។ នរណាម្នាក់ដែលស្វែងរកសេចក្តីសុខដោយបៀតបៀនអ្នកដទៃដែលស្វែងរកសេចក្តីសុខដែរនោះ នឹងមិនអាចជួបប្រទះសេចក្តីសុខឡើយ។ សំរាប់មិត្តរបស់អ្នកគឺដូចរូបអ្នក។ គេចង់បានទទួលនូវសេចក្តីសុខដែរ។ ចូរកុំធ្វើឱ្យគេចុកចាប់។ ហើយពេលណាអ្នកលាចាកលោកនេះទៅអ្នកនឹងអាចបាននូវសេចក្តីសុខនាលោកខាងនាយ” ។

“All beings tremble before violence. All fear death. All love life. See yourself in others. Then whom can you hurt?. What harm can you do?. He who seeks happiness by hurting those who seek happiness will never find happiness. For your brother is like you. He wants to be happy. Never harm him. And when you leave this life, you too will find happiness.”

ចំពោះករណីដែលព្រះសម្មាសម្ពុទ្ធហាមមិនអោយសំឡាប់សត្វនិងបៀតបៀនសត្វនេះ មានប្រជាជនជាច្រើនដែលឆ្ងល់ថាហេតុអ្វីបានជាព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឱ្យព្រះភិក្ខុសង្ឃឆាន់សាច់បាន។ គេគិតថា ការធ្វើដូច្នោះ ជាការសំឡាប់សត្វដោយប្រយោល។ បញ្ហានេះមិនមែនកើតឡើងតែក្នុងពេលសព្វថ្ងៃទេ គឺធ្លាប់កើតមានឡើងតាំងតែពីពេលដែលព្រះដ៏មានព្រះភាគទ្រង់គង់ធម្មានៅឡើយម្លេះ។បញ្ហាបរិភោគសាច់នេះជាពរមួយក្នុងចំណោមពរទាំង៥ប្រការ[1] ដែលទេវទត្តៈបានសុំពីព្រះសម្មាសម្ពុទ្ធជាម្ចាស់។ ទេវទត្តៈបានបំបែកបក្សពួករបស់ខ្លួនចេញពី ការគ្រប់គ្រងរបស់ព្រះពុទ្ធ ទៅតាំងក្រុមរបស់ខ្លួនឯងថាជាក្រុមបរិសុទ្ធិមិនបរិភោគសាច់ជាដើម។ មិនតែប៉ុណ្ណោះនៅឆ្លៀតមកបៀតបៀនប្រទូសរ៉ាយព្រះពុទ្ធឱ្យលោហិតហូរធ្លាក់ចុះទៀតផង ទើបនៅទីបំផុត ព្រះធរណីក៏ស្រូបយកទាំងរស់។ ការធ្វើបាបអនន្តរិយកម្មនេះ កើតឡើងអំពីធម៌ច្រណែននិងការចង់ឈ្នះព្រះសម្មាសម្ពុទ្ធរបស់ទេវទត្តៈ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បង្គាប់ដល់ព្រះភិក្ខុសង្ឃថា សេចក្តីបរិសុទ្ធិក្នុងការឆាន់សាច់របស់ព្រះភិក្ខុសង្ឃគឺស្ថិតនៅលើកត្តាបីយ៉ាង <u>**ទីមួយ**</u> ព្រះភិក្ខុមិនបានឃើញគេសំឡាប់សត្វនោះដោយចក្ខុផ្ទាល់ <u>**ទីពីរ**</u> ព្រះភិក្ខុសង្ឃមិនបានឮសំលេងសត្វដែលគេសំឡាប់ និង<u>**ទីបី**</u> ព្រះភិក្ខុសង្ឃមិនមានមន្ទិលសង្ស័យចំពោះសាច់ដែលកំពុងតែឆាន់។ម្យ៉ាងវិញទៀតសេចក្តីបរិសុទ្ធិមិនមែនស្ថិតនៅលើការមិនបរិភោគសាច់នោះទេ សេចក្តីបរិសុទ្ធិរបស់មនុស្សគឺស្ថិតនៅលើការមិនធ្វើនូវបាបទាំងពួង ការ

---

១. ពរទាំង៥យ៉ាងនោះគឺ

- សូមឱ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត
- សូមឱ្យភិក្ខុទាំងឡាយបិណ្ឌបាតជាវត្តអស់មួយជីវិត
- សូមឱ្យភិក្ខុទាំងឡាយប្រើប្រាស់សំពត់បង្សុកុលជាវត្តអស់មួយជីវិត
- សូមឱ្យភិក្ខុទាំងឡាយនៅទៀបគល់ឈើជាវត្តអស់មួយជីវិត
- សូមឱ្យភិក្ខុទាំងឡាយមិនឆាន់ត្រីនិងសាច់អស់មួយជីវិត

(វិន័យបិដក មហាវិភង្គ ទុតិយភាគ លេ៦២ ទំព័រ២៩២)

ធ្វើតែអំពើកុសល  និងការជំរះសន្តានចិត្តរបស់ខ្លួនឱ្យបរិសុទ្ធ ។  បើយើងសំឡឹងមើលតាមតថភាពពិតនៃជីវិតប្រចាំថ្ងៃរបស់យើង  មនុស្សលោកយើងមិនអាចជៀសវាងពីការសំលាប់ជីវិត  ដើម្បីការរស់រានមានជីវិតបានឡើយ  ជួនកាលអ្នកខ្លះអះអាងថាខ្លួនជាមំសាវិរត្តិ  តែអន្ទក់ឬបន្លែដ៏ប្រណីតដែលខ្លួនបរិភោគនោះបានមកពីការថែទាំយ៉ាងល្អមានការសំឡាប់សត្វល្អិតជាដើម ។  ឬជួនកាលប្រើភួយសំលៀកបំពាក់  ខ្សែក្រវ៉ាត់ដែលផលិតអំពីស្បែកឬរោមសត្វថែមទៀត ។

បាបដែលកើតពីកម្មដែលធ្ងន់ជាងគេគឺការមានចេតនា  ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "**ចេតនាហំ ភិក្ខវេ កម្មំ វទាមិ**" ប្រែថា "*ម្នាលភិក្ខុ តថាគតពោលថា ចេតនាជាតួកម្ម*" ។  ព្រះពុទ្ធអង្គបានទ្រង់ហាមព្រះភិក្ខុសង្ឃមិនឱ្យបរិភោគសាច់សត្វមានតែ១០[២] ប្រភេទប៉ុណ្ណោះ  ដូចជា  សាច់មនុស្ស  សាច់ដំរី  សាច់សេះ  សាច់ឆ្កែ  សាច់ពស់  សាច់រាជសីហ៍  សាច់ខ្លាឃ្មុំ  សាច់ខ្លាដំបង  សាច់ខ្លាធំ  និង  សាច់ឆ្កែព្រៃឬចចក ។

## **ប្រជាធិបតេយ្យ** (ជាតំរូវការចាំបាច់របស់មនុស្ស)

Democracy (the human's need)

ព្រះពុទ្ធសាសនាត្រូវបានគេទទួលស្គាល់ថាជាសហគមន៍ប្រជាធិបតេយ្យចាស់ទុំមួយមុនគេ ។  តាមរយៈទ្រឹស្តីក៏ដូចជាតាមរយៈការបដិបត្តិប្រចាំថ្ងៃ  សុទ្ធតែបញ្ជាក់នូវផ្គត់គំនិតជាប្រជាធិបតេយ្យទាំងអស់ ។  តាមរយៈទ្រឹស្តី  ព្រះពុទ្ធអង្គជាអ្នកនាំមុខគេ  ក្នុងការធ្វើកំណែទំរង់ប្រទេសឥណ្ឌាបុរាណដែលគ្រប់គ្រងដោយវណ្ណៈធំៗទាំងបួនយ៉ាងតឹងតែង  មានវណ្ណៈ *ព្រាហ្មណ៍  ក្សត្រ  វាណិជ* និង *សូទ្រ* មកជាបរិស័ទបួនគឺ *ព្រះភិក្ខុ  ព្រះភិក្ខុណី  ឧបាសក  ឧបាសិកា* ដែលបរិស័ទទាំងបួននេះមិនមែនទាបខ្ពស់ជាងគ្នាដោយកំណើតឬដោយការកំណត់ពីព្រះអាទិទេព្យនោះទេ  តែគេទាំងនេះខុសគ្នាដោយគុណធម៌  ការប្រព្រឹត្ត  ការព្យាយាម  និងការលះបង់ ។  កំណែទំរង់នេះ  ព្រះពុទ្ធអង្គបានផ្លាស់ប្តូរដោយមិនមានការបង្ហូរឈាម  សូម្បីតែមួយដំណក់ក៏គ្មានដែរ ។  ការស្មើភាពគ្នាគឺអាស្រ័យកម្មតែរៀងៗខ្លួន ។  កម្មជាអ្នកកំណត់ ។  មនុស្សម្នាក់អាចមានលទ្ធភាពក្លាយទៅស្តេច  ជាព្រាហ្មណ៍ជាអ្នកជំនួញស្តុកស្តម្ភ  ឬជាអ្នកសុំទានគេ  អាស្រ័យកម្មដែលខ្លួនប្រព្រឹត្តិ ។  បើធ្វើល្អទទួលបានផលល្អ

---

២. មនុស្សមំសៈ,  ហត្ថិមំសៈ,  អស្សមំសៈ,  សុនខមំសៈ,  អហិមំសៈ,  សីហមំសៈ,  ព្យគ្ឃមំសៈ,  ទិមិមំសៈ,  អច្ឆមំសៈ,  និងតិរច្ឆានមំសៈ

បើធ្វើអាក្រក់នឹងទទួលបានផលអាក្រក់។ បរិស័ទទាំងបួននៅក្នុងសហគមន៍របស់ព្រះពុទ្ធអង្គប្រៀបប្រដូចនឹងទឹកសមុទ្រដែលមានរស់ជាតិតែមួយគឺប្រៃ ទោះបីមានទឹកស្ទឹង អូរ ព្រែក បឹងបួហូរចាក់យ៉ាងណាក៏ដោយ ទឹកសមុទ្រក៏នៅតែប្រៃដដែល។ ព្រះធម៌និងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធមានរសជាតិតែមួយដូចទឹកសមុទ្រដែរគឺវិមុត្តិរស(the taste of freedom)។ ហើយព្រះធម៌នេះគឺជាច្បាប់រដ្ឋធម្មនុញ្ញកំពូលរបស់ប្រទេសជាតិនីមួយៗ ដែលប្រជាជនគ្រប់លំដាប់ថ្នាក់ត្រូវតែគោរព។

តាមរយៈទ្រឹស្តីដូចគ្នាដែរ ព្រះពុទ្ធអង្គទ្រង់សំដែងអំពីអធិបតេយ្យធម៌បីយ៉ាង(supremacy)។ មានដូចជា *អត្តាធិបតេយ្យ*(supremacy of self) គឺការយកខ្លួនឯងជាធំ ហើយការយកខ្លួនឯងជាធំនេះបានក្លាយទៅជាប្រពន្ធ័គ្រប់គ្រងផ្តាច់ការនិយម បើនិយាយតាមការរបស់លោកីយ៍។ តែបើនិយាយតាមធម៌ មានន័យថា ជាការអប់រំខ្លួនឯងផ្តាច់ឱ្យផុតពីគ្រោះអវិជ្ជា។ ទីពីរ*លោកាធិបតេយ្យ*(supremacy of the public opinion) គឺការយកសំលេងភាគច្រើនឬសាធារណជនជាធំ ប៉ុន្តែការបដិបត្តិបែបនេះជា និច្ចជាកាលនាំទៅរកភាពអនាធិបតេយ្យ(anarchy) វឹកវរច្របូកច្របល់ ពិបាកនឹងរកភាពចុះសំរុងគ្នាតែមួយបាន ព្រោះមនុស្សដប់មានចិត្តដប់ “ **នានា ចិត្តំ**” ។ តែបើនិយាយតាមធម៌ លោកាធិបតេយ្យគឺសំដៅយកមនុស្សភាគច្រើនដែលខ្ពង់ខ្ពស់ដោយចំណេះវិជ្ជានិងគុណធម៌។ ទីបី គឺ*ធម្មាធិបតេយ្យ*(supremacy of Dhamma or righteousness) ដែលព្រះពុទ្ធបង្រៀនអោយយើងទាំងអស់គ្នាយកព្រះធម៌ជាធំ ព្រះធម៌ជាកំពូល ព្រះធម៌ជាទីពឹងទីរលឹក។ ព្រះធម៌នេះមានន័យច្រើនយ៉ាងដូចជាសភាវៈទ្រទ្រង់ សច្ចៈពិត ច្បាប់ធម្មជាតិ ច្បាប់នៃហេតុនិងផល ច្បាប់ជាតិ(state of law)និមួយៗជាដើម។ ការគោរពព្រះធម៌ដែលហៅថាច្បាប់ជាតិនេះឯង ដែលសព្វថ្ងៃយើងហៅថាលទ្ធិប្រជាធិបតេយ្យ ។ លទ្ធិប្រជាធិបតេយ្យដែលត្រឹមត្រូវ ហើយដែលប្រទេសជាច្រើនយកមកបដិបត្តិសព្វថ្ងៃនេះ គឺប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ឬដែលយើងហៅថា “ ធម្មាធិបតេយ្យ” នោះឯង ។

ចំណែកការបដិបត្តិវិញ មានសហគមសង្ឃជាគំរូស្រាប់។ ព្រះសង្ឃនៅក្នុងព្រះពុទ្ធសាសនា រស់នៅក្រោមព្រះវិន័យតែមួយ ជាក្រិតក្រមកំពូលសំរាប់ភាពផាសុខរបស់សង្ឃ។ ការបដិបត្តិសង្ឃកម្មជាគោលប្រជាធិបតេយ្យមួយដែលគួរឱ្យកត់សំគាល់ និងមានលក្ខណៈដូចការបដិបត្តិក្នុងរដ្ឋសភាសព្វថ្ងៃនេះ ដូចជាពិធីឧបសម្បទាដែលត្រូវស្ូត្រញត្តិចតុត្ថកម្ម, ពិធីបុណ្យកឋិនស្ូត្រញត្តិទុតិយកម្ម, ពិធីបញ្ចុះសីមាស្ូត្រញត្តិចតុត្ថកម្មជាដើម។ ហើយពិធីកម្មនិមួយៗត្រូវរាប់

ចំនួនសង្ឃដែលចូលរួមប្រជុំឱ្យបានគ្រប់គ្រាន់ គឺអាចប្រៀបធៀបទៅនឹងតំណាងរាស្ត្រម្នាក់ៗដែលមានសិទ្ធិនៅក្នុងសភា មានសិទ្ធិក្នុងការប្រឆាំង និងការយល់ព្រម ។ ឧទាហរណ៍ពិធីឧបសម្បទា ត្រូវមានជំនុំសង្ឃយ៉ាងតិច៥អង្គ[៣] ឡើងទៅ ដោយមានព្រះឧបជ្ឈាយ៍ ប្រៀបបាននឹងប្រធានរដ្ឋសភា ព្រះសាវនាចារ្យពីរអង្គទៀត ដែលប្រៀបបានទៅនឹងអនុប្រធានសភាទាំងពីរ ហើយព្រះសង្ឃដែលជាសមាជិក ជាគណៈបូរកៈអង្គុយជុំវិញបង្គ្រប់ខ្វ៉ុម(quorum) ដើម្បីអោយការបួសនោះមានភាពត្រឹមត្រូវ និងមិនប្រាសចាកភាពជាធម្មាធិបតេយ្យ ។

ក្រៅអំពីការគោរពច្បាប់រដ្ឋ ដើម្បីធ្វើឱ្យប្រជាធិបតេយ្យមានភាពស្រស់បំព្រង មេដឹកនាំត្រូវបដិបត្តិឱ្យត្រឹមត្រូវតាមទសពិធរាជធម៌ទាំង១០យ៉ាង មានដូចជា:

១. ទាន(generosity/charity/liberality) មានអាមិសទាន, ធម្មទាន និងអភ័យទាន
២. សីល (morality) មានសង្រួមកាយវាចាជាប្រចាំគ្រប់ឥរិយាបទទាំងអស់
៣. បរិច្ចាគ :(self-sacrifice) មានការលះបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដើម្បីបុព្វហេតុជាតិ និងប្រជាជន ។
៤. អាជ្ជវ :(honesty/integrity) មានសេចក្តីស្មោះត្រង់ចំពោះកិច្ចការខ្លួននិងប្រជារាស្ត្រខ្លួន
៥. មទ្ទវ :(kindness/gentleness) មានសេចក្តីទន់ភ្លន់ ស្លូតបូត សុភាពរាបសា
៦. តប :(self-control/non-indulgence/austerity) សង្រួមនៅក្នុងធម៌ជាប្រចាំដើម្បីដុតកំដៅ លោភៈ ទោសៈ និងមោហៈ របស់ខ្លួនដែលរមែងមកយាយីរាងកាយជារៀងរាល់ពេល ។
៧. អក្កោធនៈ(non-anger/non-fury) មិនបណ្តុះសេចក្តីក្រោធខឹងឱ្យមានក្នុងសន្តាន
៨. អវិហឹង្សា(non-violence/non-oppression) មិនចងគំនុំគំគួនគិតព្យាបាទបៀតបៀនអ្នកដទៃ
៩. ខន្តិ(patience/forbearance) បណ្តុះសេចក្តីអត់ធន់ឱ្យមានក្នុងសន្តានរបស់ខ្លួន
១០. អវិរោធន :(conformity to the law) គោរពតាមច្បាប់ឱ្យត្រឹមត្រូវឱ្យបានជាគំរូដល់ប្រជារាស្ត្រទាំងពួង ជាពិសេសច្បាប់តុលាការនិងប្រព័ន្ធយុត្តិធម៌ ។

---

៣. ក្នុងព្រះវិន័យ បើនៅបច្ចន្តបទេស (ជនបទ) ព្រះពុទ្ធអនុញ្ញាតឱ្យមានគណៈបូរកៈសង្ឃតែ៥អង្គឡើងទៅបាន តែបើនៅមជ្ឈិមបទេស (មណ្ឌលសង្ឃ) គឺគួរមានយ៉ាងតិច២១អង្គឡើងទៅ ។

## សន្តិភាព

PEACE

នៅក្នុងគម្ពីរធម្មបទកថា ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងថា “ **នត្ថិ សន្តិ បរំ សុខំ និព្វានំ បរមំ សុខំ**” ប្រែថា “ *សេចក្តីសុខដទៃស្មើដោយសេចក្តីស្ងប់ពុំមានឡើយ ព្រះនិព្វានជាបរមសុខ*” ។ សេចក្តីស្ងប់ជាភាសាខ្មែរ ត្រូវគ្នានឹងភាសាបាលីថាសន្តិភាព។ សន្តិភាពតាមន័យព្រះពុទ្ធសាសនា មានពីរយ៉ាងគឺសន្តិភាពផ្លូវកាយវាចា និងសន្តិភាពផ្លូវចិត្ត។ ពេលផ្លូវកាយបានវៀរចាកពីការសំលាប់ បៀតបៀន ធ្វើទុក្ខបុកម្នេញជីវិត, ការបោកប្រាសកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ហើយផ្លូវវាចាមានការវៀរចាកពីការនិយាយកុហក់ និយាយញុះញង់ចាក់ដោតនិយាយពាក្យអាសអាភាស និងនិយាយពាក្យរោយរាយឥតប្រយោជន៍ ទើបឈ្មោះថាបានធ្វើសន្តិភាពផ្លូវកាយវាចាឱ្យមានឡើងនៅក្នុងសន្តានខ្លួន។ ពេលចិត្តដែលមានសភាពស្ងប់ប្រកបដោយសមាធិ ទើបមានឈ្មោះថាសន្តិភាពផ្លូវចិត្ត។ សន្តិភាពដទៃមិនអាចប្រៀបបានស្មើនឹងសន្តិភាពផ្លូវចិត្តឡើយ ដែលសន្តិភាពនេះស្ថិតលើអលោភៈ អទោសៈ និងអមោហៈ។ នៅពេលដែលមនុស្សលោកយើង អាចកាត់បន្ថយនូវលោភៈ ទោសៈ និងមោហៈ ភាពជាអត្តទត្ថបុគ្គល (selfishness) នឹងថយចុះផងដែរ។ សព្វថ្ងៃ ពិភពលោករបស់យើងរោលរាលក្តៅគគុកក៏ព្រោះតែយើងម្នាក់ៗមើលឃើញតែប្រយោជន៍ផ្ទាល់ខ្លួន មានសេចក្តីចង់បានលោភលន់ហួសប្រមាណ ដែលជានិច្ចជាកាលនាំទៅរកសេចក្តីក្រេវក្រោធនិងការវង្វេងវង្វាន់តាមមកឥតដាច់ ចាក់ស្រេះខ្លួនប្រាណដូចជាច្រវ៉ាក់ ។

ការប្រកាន់ខ្លួន ទិដ្ឋិអាស្មិមានៈ និងអវិជ្ជាជាសាហេតុចំបងដែលនាំទៅរកជំលោះទាស់ទែងគ្នា សំលាប់រង្គាលគ្នាឥតឈប់ឈរ។ រយៈពេល៤៥ព្រះវស្សា ព្រះពុទ្ធជាម្ចាស់ប្រកាសធម៌តែម្យ៉ាងគឺការមិនប្រកាន់ខ្ជាប់នូវតួខ្លួន តួអញ របស់អញ ដែលជាកត្តានាំទៅរកជំលោះ ការប្រកាន់ជ្រុលឬអសន្តិភាពក្នុងសង្គម។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា “ **សព្វេ ធម្មា នាលំ អភិនិវេសាយៈ**” ប្រែថា “ *ធម៌ទាំងឡាយទាំងពួង មិនឱ្យយើងចូលទៅជាប់ជំពាក់ឬប្រកាន់ជ្រុលឡើយ*” ។ ជាធម្មតាបើមនុស្សយើងមានភាពប្រកាន់ខ្លួន(egotism) កាន់តែថយចុះ មេត្តាធម៌(compassion)នឹងកាន់តែកើនឡើង, ហើយពេលណាយើងម្នាក់ៗមានមេត្តាធម៌ ពិភពលោកយើងនឹងមានសន្តិភាពយ៉ាងពិតប្រាកដ។ ការប្រកាន់រមែងមានឫសគល់របស់វាពីលោភៈ ទោសៈ

មោហៈ និងមិច្ឆាទិដ្ឋិជាដើម។ លោភៈ ទោសៈ មោហៈ និងមិច្ឆាទិដ្ឋិប្រៀបប្រដូចនឹងភ្លើងដ៏ក្តៅគគុក ដូចដែលព្រះពុទ្ធអង្គត្រាស់នៅក្នុងគម្ពីរធម្មបទថា :

" គ្មានភ្លើងណាក្តៅដូចជាលោភៈ គ្មានឧក្រិដ្ឋកម្មណាសាហាវដូចជាទោសៈ គ្មានសេចក្តីទុក្ខណាស្មើនឹងការបែកបាក់ព្រាត់ប្រាស់ គ្មានជំងឺឈឺថ្កាត់ណាដូចជាជំងឺស្រេកឃ្លាននូវសេចក្តីស្រលាញ់ ហើយគ្មានសេចក្តីសុខណាស្មើនឹងមានសេរីភាព។ សុខមាលភាព សេចក្តីពេញចិត្តក្នុងអារម្មណ៍ និងការជឿជាក់ក្នុងចិត្ត គឺជាទ្រព្យសម្បត្តិដ៏អស្ចារ្យ ហើយសិទ្ធិសេរីភាពគឺជាសេចក្តីសុខដ៏ក្រៃលែង។ ចូរសំឡឹងមើលខ្លួនឯង។ ចូរមិនញាប់ញ័រ។ ចូររំដោះខ្លួនឱ្យចេញផុតពីការភ័យខ្លាចនិងឧបាទាន, ស្គាល់នូវសេចក្តីសុខនៃជីវិតដែលកើតអំពីការរស់នៅយ៉ាងសាមញ្ញធម្មតា" ។

"There is no fire like greed, no crime like hatred, no sorrow like separation, no sickness like hunger of heart, and no joy like the joy of freedom. Health, contenment and trust are your greatest possessions and freedom is your greatest joy. Look within. Be still. Free from fear and attachment, know the joy of living in the way." *Dhammapada*

ព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ជាក់នូវរូបមន្តសន្តិភាពថា :

" ពៀរមិនដែលរំងាប់ដោយការចងពៀរទេ នៅក្នុងលោកយើងនេះ, តែពៀរត្រូវរំងាប់ដោយមេត្តាធម៌។ នេះគឺជាអមតធម៌។

"Hatred is never appeased by hatred in this world; it is appeased by compassion. This is an eternal law". *Dhammapada*

## **ព្រះនិព្វាន**

Nibbana or Nirvana

សត្វលោកទាំងអស់មានគោលបំណងតែមួយដូចគ្នា គឺគេស្អប់នូវសេចក្តីទុក្ខហើយប្រាថ្នានូវសេចក្តីសុខ ដែលគោលដៅនៃសេចក្តីសុខនោះជាសេចក្តីសុខដ៏ឧត្តមដែលយើងហៅថាបរមសុខឬព្រះនិព្វាន។ ព្រះនិព្វានមិនមែនជាឋានទទេ(emptiness) មិនមែនជាបរិសូន្យ(annihilation)ឬមិនមែនប្រែថាស្លាប់ (death) ទេ។ ព្រះនិព្វានជាបរមសុខ(highest bliss) ជាការសំរេចធម៌ជាន់ខ្ពស់ (supreme attainment) ជាទិសដៅតែមួយ(single goal)របស់សត្វលោកទាំងអស់ ទោះបីគេត្រូវតែទៅដល់មុនឬទៅដល់ក្រោយក៏ដោយ តែសត្វលោកទាំងអស់ចុងបញ្ចប់គឺនឹងសំរេចនូវព្រះនិព្វាន។ ពេលមនុស្សយើងបានទទួលសិទ្ធិសេរីភាពគ្រប់គ្រាន់, មានសេរីភាពទាំងការបំពេញ

ការងារនិងបញ្ចេញមតិតាមគន្លងប្រជាធិបតេយ្យ និងមានសន្តិភាពទាំងផ្លូវកាយ វាចា និងចិត្ត គេច្បាស់ជាបានសំរេចនូវសេចក្តីសុខដ៏ខ្ពង់ខ្ពស់បំផុត។ សេចក្តីសំរេចនូវសុខសន្តិភាពដ៏ខ្ពង់ខ្ពស់នេះ អាចប្រព្រឹត្តទៅបានត្រូវអាស្រ័យច្បាប់ ដែលជាចលករដ៏ត្រឹមត្រូវនិងសំខាន់បំផុតនាំទៅរកបរមសុខ ឬព្រះនិព្វាន។ ច្បាប់ឬក្រិតក្រមនោះ ត្រូវឈរនៅលើផ្លូវកណ្តាល តាមមជ្ឈិមបដិទាប្រកបដោយ អង្គ ៨ មានដូចជា :

១. សម្មាទិដ្ឋិ(right understanding) គឺមានគំនិតយល់ឃើញច្បាស់នៅក្នុងអរិយសច្ច៤
២. សម្មាសង្កប្ប: (right thought)គឺការត្រិះរិះពិចារណាត្រឹមត្រូវដោយឈរលើការគិត ចង់ចេញចាកកាម, ការគិតមិនព្យាបាទ និងការគិតមិនបៀតបៀន ។
៣. សម្មាវាចា(right speech) គឺសំដីត្រឹមត្រូវដោយវៀរចាកការនិយាយកុហក់ និយាយ ញុះញង់ចាក់ដោត និយាយពាក្យអសុរស និងនិយាយរោយរាយ ឥតប្រយោជន៍ ។
៤. សម្មាកម្មន្ត :(right action) គឺការងារត្រឹមត្រូវ ដោយប្រាសចាកការសំលាប់ ការលួចប្លន់ ការប្រព្រឹត្តរំលោភលើប្រពន្ធកូនអ្នកដទៃ ។
៥. សម្មាអាជីវ :(right livelihood) គឺចិញ្ចឹមជីវិតត្រឹមត្រូវ ដោយវៀរចាកការ ធ្វើជំនួញខុស៥យ៉ាង មានដូចជាជួញមនុស្ស ជួញសាច់ស្រស់ ជួញអាវុធ ជួញថ្នាំ ពិស និងជួញគ្រឿងស្រវឹង ឬថ្នាំញៀនជាដើម ។
៦. សម្មាវាយាម :(right effort) គឺព្យាយាមត្រឹមត្រូវ ដោយព្យាយាមវៀរចាកពី អំពើបាបទាំងពួង ប្រឹងលះបង់អំពើបាបដែលមាននៅក្នុងសន្តាន ព្យាយាមធ្វើតែអំពើ កុសល និងព្យាយាមរក្សាអំពើកុសលឱ្យមាននៅក្នុងសន្តាន ។
៧. សម្មាសតិ(right mindfulness) គឺមានសេចក្តីភ្ញាក់រលឹកត្រឹមត្រូវជានិច្ចទោះបីតាម ផ្លូវកាយ ផ្លូវវេទនា ផ្លូវចិត្ត និងផ្លូវធម៌ ។
៨. សម្មាសមាធិ(right meditation)គឺមានសេចក្តីតំកល់ចិត្តនឹងមួយកន្លែង(pointedness) មិនរំជើបរំជួល ដោយសេចក្តីសុខឬសេចក្តីទុក្ខ ។



## ឯកសារយោង


១. មេត្តាបាលោ ទឹម សឿត, សង្ឃទានមានផលច្រើន, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ព.ស.២៥៤៥, គ.ស.២០០១

2. Karen Armstrong, The Life of Lord Buddha, Penguin Lives, 2004

3. Dhamma Pitaka, Dictionary of Buddhism, Mahachulalongkornlongkorn, Bangkok, B.E.2538